Disability Rights California

*ប្រព័ន្ធការការពារ និងការតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*

*ទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# ភាពជាអ្នកមើលការខុសត្រូវមនុស្សធំដែល មានដែនកំណត់ និងជម្រើសផ្សេងទៀត

**ខែតុលា ឆ្នាំ 2015 ការបោះពុម្ពផ្សាយលេខ 5578.06**

## 1. តើភាពជាអ្នកមើលខុសត្រូវមនុស្សធំ (conservatorship) ជាអ្វី?

ភាពជាអ្នកមើលថែមនុស្សធំគឺជាដំណើរការរបស់តុលាការដែលចៅក្រុម សម្រេចថាអ្នកមានលទ្ធភាពអាចមើលថែសុខភាព រៀបចំអាហារ សម្លៀកបំពាក់ ទីជម្រក ប្រាក់កាស ឬតម្រូវការផ្ទាល់ខ្លួនដោយខ្លួនឯងបាន ដែរឬទេ ។ តុលាការអាចដកហូតសិទ្ធិសំខាន់ៗទាំងនេះពីអ្នក ។ អ្នកទទួលខុសត្រូវមើលថែអ្នក អាចត្រូវបានតែងតាំងដោយតុលាការ សម្រាប់ធ្វើការសម្រេចចិត្តនានាសម្រាប់អ្នក ។ តុលាការហៅមនុស្សនេះថា “អ្នកមើលការខុសត្រូវមនុស្សធំ” (conservator) ។ តុលាការហៅអ្នកថាជា “អ្នកដែលត្រូវឲ្យគេមើលថែ“ (conservatee) ។ ភាពជាអ្នកមើលការខុសត្រូវមនុស្សធំ គឺមានសម្រាប់តែ មនុស្សដែលមានអាយុ 18 ឆ្នាំឡើង ។

## 2. តើភាពជាអ្នកមើលការខុសត្រូវមនុស្សធំ មានប៉ុន្មានប្រភេទ?

នៅរដ្ឋកាលីហ្វ័រនីញ៉ា ភាពជាអ្នកមើលការខុសត្រូវមនុស្សធំមានច្រើន ប្រភេទ ៖

- ភាពជាអ្នកមើលការខុសត្រូវមរតកទូទៅ (General Probate Conservatorship)

- ច្បាប់ការប្រគល់អ្នកជម្ងឺវិកលចរិកទៅឲ្យមណ្ឌលថែទាំ (Lanterman Petris Short Act)

- ភាពជាអ្នកមើលការខុសត្រូវមនុស្សវិកលចរិក (Dementia Conservatorship)

- ភាពជាអ្នកមើលការខុសត្រូវដែលមានដែនកំណត់ (Limited Conservatorship)

## 3. តើភាពជាអ្នកមើលការខុសត្រូវមានដែនកំណត់ ជាអ្វី?

ភាពជាអ្នកមើលការខុសត្រូវមានដែនកំណត់ គឺជាប្រភេទការមើលខុសត្រូវមនុស្សធំ ដែលត្រូវបានបង្កើតឡើងសម្រាប់មនុស្សដែលមានពិការភាពខួរក្បាល ។ វាត្រូវបានគេបង្កើតឡើង ដើម្បីធានាថាអ្នកអាចពឹងលើខ្លួនឯង និងរស់នៅដោយខ្លួនឯងបានច្រើនជាទីបំផុត ។ វាអនុញ្ញាតឲ្យអ្នកអាចរក្សាទុកបាននូវសិទ្ធិមួយចំនួន ដើម្បីឲ្យអ្នកអាចសម្រេចចិត្តបានមួយចំនួនអំពីជីវិតរបស់អ្នក ។ តុលាការនឹងសម្រេចថាតើការសម្រេចចិត្តអ្វីខ្លះដែលអ្នកមើលថែមនុស្សធំអាចសម្រេចឲ្យអ្នកបាន ។

## 4. តើនរណាដែលតុលាការអាចចាត់តាំងឲ្យធ្វើជាអ្នកមើលការខុសត្រូវមនុស្សធំមានដែនកំណត់សម្រាប់អ្នក?

មនុស្សដែលត្រូវបានតែងតាំងជាអ្នកមើលការខុសត្រូវមនុស្សធំដែលមានដែនកំណត់ ត្រូវតែជាមនុស្សដែលមានអាយុ 18 ឆ្នាំឡើង ហើយធ្វើអ្វីដើម្បីជាប្រយោជន៍របស់អ្នកច្រើនជាទីបំផុត ។ អ្នកអាចស្នើសុំឲ្យតុលាការតែងតាំងនរណាម្នាក់ដែលអ្នកស្គាល់ ដូចជាសមាជិកគ្រួសារ ឬមិត្តភ័ក្ត តែចៅក្រមគឺជាអ្នកសម្រេចថានរណាជាអ្នកមើលការខុសត្រូវ ដែលមានដែនកំណត់របស់អ្នក ។ តុលាការអាចចាត់តាំងអ្នកមើលការខុសត្រូវមនុស្សធំមានដែនកំណត់ច្រើនជាងមួយនាក់ (សហអ្នកមើលខុសត្រូវមនុស្សធំ) ។ ចំពោះករណីខ្លះ តុលាការចាត់តាំងអ្នកជំនាញឯកជនឲ្យធ្វើជាអ្នកមើលខុសត្រូវសម្រាប់អ្នក ។ អាណាព្យាបាលសាធារណៈរបស់ខោនធី អាចត្រូវតែងតាំងជាមនុស្សសម្រាប់មើលការខុសត្រូវអ្នក បើតុលាការរកអ្នកផ្សេងមិនបានទេនោះ ។

## 5. តើគេបង្កើតអ្នកមើលការខុសត្រូវមនុស្សធំមានដែនកំណត់ដោយរបៀបណា?

- អ្នកដែលត្រូវបានគេស្នើឲ្យធ្វើជាអ្នកមើលខុសត្រូវមនុស្សធំ ដាក់ញត្តិទៅកាន់តុលាការ ។

- សំណៅចតចម្លងនៃញត្តិនេះត្រូវទុកឲ្យអ្នកមួយច្បាប់ ។
- សំណៅចតម្លងញត្តិផ្សេងទៀត ត្រូវផ្ញើទៅឲ្យសាច់ញាតិអ្នក និង ភ្នាក់ងារមួយចំនួន ដូចជាមជ្ឈមណ្ឌលប្រចាំតំបន់ (regional center) ។
- អ្នកស៊ើបអង្កេតរបស់តុលាការ ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវសំណុំរឿងរបស់អ្នក ។
- អ្នកត្រូវទៅចូលរួមសវនាការ ប្រសិនបើមិនមានការយល់ព្រមពីចៅក្រមថា លើកលែងទេនោះ ។
- ចៅក្រមនឹងចាត់តាំងមេធាវីសម្រាប់តំណាងរូបអ្នក ។

## 6. តើអ្នកស៊ើបអង្កេតរបស់តុលាការ មានតួនាទីអ្វីខ្លះ ចំពោះ ដំណើរការបង្កើតអ្នកមើលការខុសត្រូវមនុស្សធំដែលមាន ដែនកំណត់?

អ្នកស៊ើបអង្កេតរបស់តុលាការត្រូវតែ ៖
- ពន្យល់ និងពិនិត្យឡើងវិញនូវញត្តិជាមួយអ្នក ។
- សម្ភាសន៍ និងប្រាប់អ្នកអំពីដំណើរការបង្កើតភាពជាអ្នកមើលការខុសត្រូវឲ្យអ្នកបានដឹង ។
- កំណត់ថាតើអ្នក ៖
    - អាចទៅចូលរួមសវនាការបានដែរឬទេ
    - ត្រូវការសួរសំណួរប្រឈមចំពោះការបង្កើតភាពជាអ្នកមើលការខុសត្រូវសម្រាប់អ្នកដែរឬទេ
    - មិនយល់ស្របចំពោះសំណើរផ្តល់អ្នកមើលការខុសត្រូវសម្រាប់អ្នក ឬ ចង់ឲ្យអ្នកផ្សេងធ្វើជាអ្នកមើលការខុសត្រូវ រូបអ្នក ។

## 7. តើមជ្ឈមណ្ឌលប្រចាំតំបន់មានតួនាទីអ្វីខ្លះក្នុងភាពជាអ្នក មើលការខុសត្រូវមនុស្សធំមានដែនកំណត់?

ជាមួយនឹងការយល់ព្រមរបស់អ្នក មជ្ឈមណ្ឌលប្រចាំតំបន់ ត្រូវវាយតម្លៃរូបអ្នក ហើយដាក់ស្នើរបាយការណ៍ទៅកាន់តុលាការ ។ របាយការណ៍ត្រូវរួមបញ្ចូលនូវ ៖
    - ស្ថានភាព/កម្រិតពិការភាពរបស់អ្នក ។

- ជំនួយដែលអ្នកត្រូវការ ។
- ស្ថានភាពរាងកាយរបស់អ្នក ។
- ស្ថានភាពផ្លូវចិត្ត និងសុខុមាលភាពសង្គមរបស់អ្នក ។
- អនុសាសន៍អំពីសិទ្ធិជាក់លាក់ដែលបានស្នើសុំនៅក្នុងញត្តិ ។

បើអ្នកមើលការខុសត្រូវដែលបានស្នើ ជាអ្នកផ្តល់សេវាកម្មថែទាំសុខភាព របាយការណ៍ត្រូវតែ

- ដាក់បញ្ចូលយោបល់ថាតើអ្នកផ្តល់សេវាកម្មមើលការខុសត្រូវ គឺជាមនុស្សសមរម្យដែលអាចជួយអ្នកទៅតាមតម្រូវការបានដែរឬទេ ។
- សំណៅនៃរបាយការណ៍នេះត្រូវផ្ញើទៅឲ្យអ្នក និងមេធាវីរបស់អ្នក ឲ្យបានយ៉ាងហោចណាស់ក៏ 5 ថ្ងៃមុនការបើកសវនាការដែរ ។

## 8. តើនៅក្នុងដំណើរការបង្កើតអ្នកមើលថែទាំមានដែនកំណត់ ខ្ញុំមានសិទ្ធិអ្វីខ្លះ?

អ្នកមានសិទ្ធិ ៖
- ដឹងថាតើសិទ្ធិអ្វីខ្លះដែលតុលាការនឹងដកហូតពីអ្នក និងថាតើពេលមានអ្នកមើលថែ តើវាមានផលប៉ះពាល់ដូចម្តេចខ្លះចំពោះសិទ្ធិរបស់អ្នក ។
- ទទួលបានសេចក្តីជូនដំណឹង និងសំណៅថតចម្លងនៃញត្តិស្នើសុំឲ្យមានអ្នកមើលការខុសត្រូវ យ៉ាងហោចណាស់ចំនួន 15ថ្ងៃ មុនការបើកសវនាការរបស់តុលាការ ។
- មានមេធាវីសម្រាប់តំណាងរូបអ្នក ។ បើអ្នកមិនមានមេធាវីទេ តុលាការត្រូវតែងតាំងមេធាវីម្នាក់ឲ្យអ្នក ។
- ទទួលបានសំណៅនៃរាល់របាយការណ៍ ដែលគ្រួសារអ្នក មិត្តភ័ក្ត មជ្ឈមណ្ឌលប្រចាំតំបន់ និងអ្នកដទៃបានប្រគល់ទៅឲ្យតុលាការ ។
- ចូលរួមក្នុងសវនាការបង្កើតអ្នកមើលការខុសត្រូវ ។
- ចោទសួរសំណួរប្រឈមចំពោះការបង្កើតភាពជាអ្នកមើលការខុសត្រូវ ។
- ទទួលបានការកាត់ក្តីដោយមានគណៈវិនិច្ឆ័យ បើអ្នកស្នើសុំ ។

## 9. នៅក្នុងការបង្កើតអ្នកមើលការខុសត្រូវដែលមានដែនកំណត់ តើតុលាការនឹងដកហូតសិទ្ធិអ្វីខ្លះពីខ្ញុំ?

តុកាលារអាចដកហូតសិទ្ធិមួយចំនួន ឬដកហូតទាំងអស់ក្នុងចំណោមសិទ្ធិទាំងនេះក្នុងការ ៖
- កំណត់ការស្នាក់នៅ ។
- ការចូលបើកមើលកំណត់ត្រាព័ត៌មានសម្ងាត់ ។
- រៀបការ ។
- ចុះហត្ថលេខាកិច្ចសន្យា ។
- ផ្តល់សេចក្តីយល់ព្រមសម្រាប់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ ។
- គ្រប់គ្រងទំនាក់ទំនងសង្គម និងទំនាក់ទំនងផ្លូវភេទ ។
- សម្រេចចិត្តចំពោះការអប់រំ ។

## 10. តើខ្ញុំអាចបង្ហាញតុលាការយ៉ាងណាថាខ្ញុំមិនត្រូវការអ្នកមើលការខុសត្រូវ?

អ្នកអាចបង្ហាញថា អ្នកមានលទ្ធភាពអាចមើលថែទាំសុខភាព រៀបចំអាហារ សម្លៀកបំពាក់ ជម្រកស្នាក់នៅ ប្រាក់កាស ឬតម្រូវការផ្ទាល់ខ្លួនបានដោយខ្លួនឯង ។ អ្នកអាចប្រើការជ្រោមជ្រែង និងសេវាកម្មនានា ដែលជាជម្រើសជំនួសឲ្យការមានអ្នកមើលការខុសត្រូវ បូករួមទាំងការជ្រោមជ្រែងក្នុងការសម្រេចចិត្តដើម្បីជួយអ្នក ។ សូមអានសំណួរទី 12 អំពីការរាយឈ្មោះវិធីនានា ជាជម្រើសជំនួសឲ្យការមានអ្នកមើលការខុសត្រូវ ។

## 11. បើតុលាការសម្រេចថា ខ្ញុំត្រូវមានអ្នកមើលការខុសត្រូវដែលមានដែនកំណត់ តើអ្នកមើលការខុសត្រូវខ្ញុំមានភារកិច្ច និងការទទួលខុសត្រូវអ្វីខ្លះ?

អ្នកមើលការខុសត្រូវ មានភារកិច្ចសំខាន់ដែលត្រូវធ្វើទៅតាមអ្វីដែលតុលាការបានកំណត់ឲ្យគេធ្វើ ដែលជាការសម្រេចចិត្តដើម្បីជាប្រយោជន៍ធំបំផុតសម្រាប់អ្នក ។ ចំណុចនេះ អាចរួមបញ្ចូលទាំង ៖

- ជួយអ្នកឲ្យទទួលបានសេវាកម្មជ្រោមជ្រែង ការអប់រំ សេវាកម្មវេជ្ជសាស្ត្រ និងសេវាកម្មផ្សេងទៀត ដែលអាចជួយអ្នកឲ្យមានជីវិតឯករាជ្យបានច្រើនបំផុត ។
- ការឆ្លើយតបចំពោះវិបត្តិនៅពេលត្រូវការ ។
- ជួយអ្នកចាត់ចែងតម្រូវការ ឬប្រាក់កាសផ្ទាល់ខ្លួន ។

## 12. តើអ្វីខ្លះជាវិធីសាស្ត្រដែលមានលក្ខណៈតិចជាង ជំនួសឲ្យការមានអ្នកមើលការខុសត្រូវដែលមានដែនកំណត់?

នៅពេលដែលនរណាម្នាក់អាចស្នើសុំតុលាការឲ្យតែងតាំងរូបគេជាអ្នកមើលការខុសត្រូវអ្នក ច្បាប់តម្រូវឲ្យបុគ្គលនោះ ត្រូវគិតរកវិធីផ្សេងមកជំនួស ។ វិធីផ្សេងជាជម្រើស អាចពន្យារ ឬបំបាត់ចោលនូវតម្រូវការឲ្យមានអ្នកមើលការខុសត្រូវ ។

### <u>វិធីជាជម្រើសទូទៅ</u>

### ការជ្រោមជ្រែងក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ៖

ការជ្រោមជ្រែងក្នុងការធ្វើសេចក្ដីសម្រេចចិត្ត (SDM, Supported Decision-Making) គឺប្រើនៅពេលអ្នកសុំឲ្យមិត្តភ័ក្ត គ្រួសារ និងអ្នកជំនាញដែលអ្នកជឿទុកចិត្ត ជួយពន្យល់អ្នកឲ្យបានយល់អំពី ស្ថានការ និងជម្រើសនៅក្នុងជីវិតរបស់អ្នក ។វាជាវិធីសម្រាប់បង្កើនឯករាជ្យភាពរបស់អ្នក ។ វាជម្រុញអ្នក និងផ្ដល់អំណាចឲ្យអ្នកដើម្បីធ្វើសេចក្ដីសម្រេចចិត្តអំពីជីវិតអ្នកឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។ SDM គឺជាវិធីដែលមនុស្សធំភាគច្រើនធ្វើសេចក្ដីសម្រេចចិត្តប្រចាំថ្ងៃ ។ SDM ក៏ជាវិធី ៖
- ជួយអ្នកក្នុងការធ្វើឲ្យមានអ្វីកើតឡើង ក្នុងជីវិតអ្នក ។
- ជួយអ្នកឲ្យចេះជ្រើសរើសអំពីទីកន្លែង របៀបរបប និងអ្នកណាដែលអ្នកចង់រស់នៅជាមួយ ។
- ជួយអ្នកឲ្យចេះជ្រើសរើសកន្លែងដែលអ្នកចង់ធ្វើការ ។
- ជួយអ្នកឲ្យចេះចាត់ការជីវិតរបស់អ្នក ជាជាងឲ្យអ្នកដទៃធ្វើជំនួសអ្នក ។
- ធ្វើឲ្យអ្នកកាន់តែមានគុណភាពជីវិតជាវិជ្ជមានកាន់តែច្រើនឡើង ។

- បង្កើនឱកាសការងារ ឯករាជ្យភាពចំពោះជីវិតប្រចាំថ្ងៃ និងសមាហរណកម្មសហគមន៍របស់អ្នក ។

**អំណាចដែលអ្នកផ្តល់ឲ្យ (Durable Power of Attorney)៖**

នេះជាឯកសារផ្លូវច្បាប់ ដែលអ្នកប្រគល់សិទ្ធិផ្លូវច្បាប់ឲ្យនរណាម្នាក់ដែលអ្នកជឿជាក់ ដើម្បីធ្វើការសម្រេចចិត្តសម្រាប់អ្នក ។ វាជាវិធីមួយដែលជួយឲ្យអ្នកទទួលបានជំនួយចំពោះការជ្រោមជ្រែង និងសេវាកម្មនានាដែលអ្នកត្រូវការដើម្បីអាចរស់នៅបានដោយឯករាជ្យ ។ អ្នកអាចប្រគល់សិទ្ធិឲ្យនរណាម្នាក់ក្នុងការធ្វើការសម្រេចចិត្តមួយប្រភេទ ដូចជាការសម្រេចចិត្តចំពោះការព្យាបាល ឬការសម្រេចចិត្តផ្នែកប្រាក់កាស ឬក៏ប្រគល់សិទ្ធិឲ្យគេជួយធ្វើសេចក្តីសម្រេចចិត្តទាំងពីរយ៉ាងឲ្យអ្នក ។

**វិធីជាជម្រើសទូទៅផ្សេងទៀត ៖**

- អ្នកអាចចូលរួមក្នុងក្រុមអ្នកតស៊ូមតិដើម្បីខ្លួនឯង ដូចជាក្រុម People First ឬទទួលបានការបណ្តុះបណ្តាលខ្លួនឯងផ្នែកការតស៊ូមតិដើម្បីជួយអ្នកឲ្យចេះអំពីរបៀបទំនាក់ទំនង និងតស៊ូមតិចំពោះអ្វីដែលអ្នកត្រូវការ ។
- អ្នកអាចយកជម្រើសរបស់អ្នកឲ្យគេសរសេរចូលក្នុងផែនការអប់រំតម្រូវតាមលក្ខណៈបុគ្គល (IEP, Individualized Education Program) ឬផែនការកម្មវិធីតម្រូវតាមលក្ខណៈបុគ្គល (IPP, Individualized Program Plan) របស់អ្នក ។
- អ្នកអាចត្រៀមខ្លួនសម្រាប់ចូលរួមក្នុងការរៀបចំ IEP ឬ IPP របស់អ្នក ដោយការសម្តែងតួ និងដោយនិយាយអំពីអ្វីដែលអ្នកត្រូវការ និងអ្វីដែលអ្នកចង់បាន ជាមួយនរណាម្នាក់ដែលអ្នកជឿជាក់ ។
- អ្នកអាចរកអ្នកសម្របសម្រួល ឲ្យជួយអ្នកក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា ។

## <u>*វិធីជាជម្រើសជាក់លាក់*</u>

**វិធីផ្សេងទៀត សម្រាប់ជួយអ្នកឲ្យទទួលបានសេវាកម្មនានា ដែលមានចែងក្នុង IEP ឬ IPP របស់អ្នក ៖**

អ្នកមានសិទ្ធិដើម្បីអញ្ជើញមនុស្សឲ្យចូលរួមការប្រជុំ IEP ឬ IPP របស់អ្នក ដែលនឹងជួយជ្រោមជ្រែងអ្នកក្នុងការតស៊ូមតិស្នើសុំសេវាកម្មនានាដែលអ្នកត្រូវការដើម្បីអាចរស់នៅបានដោយឯករាជ្យ ។ អ្នកតស៊ូមតិអាចជា ៖
- អ្នកសម្របសម្រួលសេវាកម្មរបស់អ្នក ។
- គ្រួសាររបស់អ្នក និងមនុស្សដែលស្ថិតក្នុងរង្វង់នៃការជ្រោមជ្រែងអ្នក ។
- អ្នកតស៊ូមតិដែលបានទទួលការបណ្តុះបណ្តាល ។

**វិធីផ្សេងទៀត ដើម្បីធ្វើការសម្រេចចិត្តថាអ្នកចង់រស់នៅទីណា និងរស់នៅជាមួយអ្នកណា ៖**

- ពិភាក្សាអំពីបំណង និងជម្រើសជាមួយនរណាម្នាក់ដែលអ្នកជឿទុកចិត្ត ដូចជា ៖
    - អ្នកស្ថិតក្នុងរង្វង់ការជ្រោមជ្រែង (មនុស្សដែលអ្នកជឿជាក់ និងអ្នកដែលជ្រោមជ្រែងអ្នក) ។
    - អ្នកផ្តល់ សេវាកម្មការរស់នៅដោយឯករាជ្យ (ILS, Independent Living Services) ។
    - អ្នកផ្តល់ សេវាកម្មជ្រោមជ្រែងការរស់នៅ (SLS, Supported Living Services) ។
    - បុគ្គលិក មណ្ឌលថែទាំសហគមន៍ (Community Care Facility) ឬបុគ្គលិក មណ្ឌលថែទាំមធ្យម (Intermediate Care Facility) ។
- សួរមនុស្សដែលអ្នកជឿជាក់ពីរបៀបសុំជំនួយការជួលផ្ទះ ឬការដាក់ពាក្យសុំជំនួយជម្រកស្នាក់នៅសាធារណៈ (Public Housing Assistance) ។
- តស៊ូមតិនៅឯការប្រជុំរៀបចំ IPP របស់អ្នក និងធ្វើឲ្យគេយកជម្រើសរបស់អ្នក សរសេរចូលក្នុង IPP របស់អ្នក ។

**វិធីសាស្ត្រផ្សេងទៀត សម្រាប់បើកមើលព័ត៌មានសម្ងាត់របស់អ្នក ៖**

បើអ្នកចង់ឲ្យនរណាម្នាក់ដែលអ្នកជឿជាក់ ទទួលបានព័ត៌មានសម្ងាត់របស់អ្នក អ្នកអាចផ្តល់ការអនុញ្ញាត ដល់អ្នកនោះ ដោយការប្រើវិធីណាមួយជាជម្រើសទាំងអស់នេះ ៖

- ចុះហត្ថលេខាលើ សំណុំបែបបទបញ្ចេញព័ត៌មានវេជ្ជសាស្ត្រនៃក្រមការធានារ៉ាប់រងសុខភាពដែលមានតម្លៃសមរម្យ និងមានគណនេយ្យភាព (HIPAA, Health Insurance Portability and Accountability Act) ។

- ចុះហត្ថលេខាលើសំណុំបែបបទយល់ព្រមឲ្យបញ្ចេញព័ត៌មាន ឬកំណត់ត្រាទិន្នន័យ ។
- អ្នក និងមនុស្សផ្សេងម្នាក់ទៀត អាចហៅទូរស័ព្ទមកកាន់ភ្នាក់ងារនេះជាមួយគ្នា ហើយអ្នកអាចផ្តល់ការអនុញ្ញាតរបស់អ្នកតាមទូរស័ព្ទ ។

**វិធីជាជម្រើសសម្រាប់ជួយអ្នកក្នុងការចាត់ចែងប្រាក់កាសរបស់អ្នក ៖**
- អ្នកអាចចុះហត្ថលេខាលើឯកសារប្រគល់សិទ្ធិឲ្យគេចាត់ចែងប្រាក់កាសឲ្យអ្នក ។ ការធ្វើបែបនេះគឺប្រគល់សិទ្ធិឲ្យនរណាម្នាក់ដែលអ្នកជឿជាក់ ឲ្យធ្វើសេចក្តីសម្រេចចិត្តអំពីហិរញ្ញវត្ថុ និងប្រាក់កាសរបស់អ្នក ។ ការប្រគល់អំណាចផ្លូវច្បាប់ក្នុងការគ្រប់គ្រងប្រាក់កាសត្រូវតែធ្វើនៅមន្ទីរសារការី ។ អ្នកអាចបញ្ចប់ការប្រគល់សិទ្ធិនេះបាននៅពេលណាដែលអ្នកចង់ ។
- អ្នកអាចជ្រើសរើសនរណាម្នាក់ឲ្យធ្វើជាអ្នកតំណាងទទួលប្រាក់ជំនួយចំនូលសន្តិសុខបង្គ្រប់ (SSI, Supplemental Security Income)/សន្តិសុខសង្គម (Social Security) របស់អ្នក ។
- មានច្បាប់ដើម្បីជួយការពារជំនួយ SSI/Social Security របស់អ្នក ។
- អ្នកអាចសុំឲ្យគេសរសេរសេវាកម្មទាំងនេះចូលក្នុង IPP របស់អ្នក ដើម្បីជួយអ្នកក្នុងការចាត់ចែងប្រាក់កាសរបស់អ្នក ដូចបុគ្គលិកផ្តល់សេវាកម្មការរស់នៅដោយឯករាជ្យរបស់អ្នក ។
- ក្រុមតម្រូវការពិសេស (Special Needs Trust) អាចត្រូវបង្កើតឡើងសម្រាប់អ្នក ។ បន្ទាប់មកគណៈកម្មការអាចចាត់ចែងប្រាក់កាសរបស់អ្នកបាន ។
- គណនីធនាគាររួមគ្នា ៖ អ្នកអាចបើកគណនីធនាគាររួមគ្នា ជាមួយនរណាម្នាក់ដែលអ្នកជឿជាក់ ដើម្បីជួយអ្នកសរសេរសែក ដាក់ ឬដកប្រាក់ ។

**វិធីផ្សេងទៀតដើម្បីជួយអ្នកពីតម្រូវការការថែទាំសុខភាព ៖**
- អ្នកអាចចុះហត្ថលេខាលើលិខិតណែនាំពីការថែទាំសុខភាពទុកជាមុន (Advance Health Care Directive) ដើម្បីឲ្យគេធ្វើតាមបំណងរបស់អ្នក ។ ចំពោះលិខិតបែបនេះ វាតម្រូវឲ្យមានហត្ថលេខាសាក្សីចំនួនពីរនាក់ ឬត្រូវ

ធ្វើនៅមន្ទីរសារការី ហើយអាចប្តូរ ឬបញ្ចប់នៅពេលណាក៏បានទៅតាមតម្រូវការរបស់អ្នក ។
- ដោយសារអ្នកជាអ្នកជម្ងឺ គ្រូពេទ្យត្រូវប្រាប់អ្នកអំពីហានិភ័យ និងអត្ថប្រយោជន៍នៃការព្យាបាល ការព្យាបាលតាមវិធីផ្សេងទៀត ដែលមានផ្តល់ជូន និងប្រាប់អ្នកពីអ្វីដែលអាចកើតឡើងបើមិនមានការព្យាបាលទេនោះ ។
- បើអ្នកមិនអាចធ្វើសេចក្តីសម្រេចចិត្តបានទេនោះ ៖
    - សាច់ញាតិជិតបំផុតរបស់អ្នក ដែលមានវត្តមាន (ដូចជាឪពុកម្តាយ) អាចផ្តល់សិទ្ធិលើការថែទាំសុខភាពសម្រាប់អ្នក ។
    - មជ្ឈមណ្ឌលប្រចាំតំបន់របស់អ្នកអាចផ្តល់សិទ្ធិការថែទាំវេជ្ជសាស្ត្រ ការវះកាត់ ឬការថែទាំធ្មេញមួយចំនួន ចំពោះស្ថានភាពខ្លះ ។
    - គ្រូពេទ្យ ឬទន្តពេទ្យ អាចធ្វើសេចក្តីសម្រេចចិត្តបានក្នុងករណីគ្រាអាសន្ន ។
- ការប្រគល់សិទ្ធិរបស់តុលាការ គឺជាភាពតម្រូវ ចំពោះប្រតិបត្តិការវេជ្ជសាស្ត្រជាក់លាក់មួយចំនួន ។
- បើអ្នកជាមនុស្សរស់នៅក្នុងមណ្ឌលថែទាំមធ្យម (ICF, Initermediate Care Facility)/មណ្ឌលថែទាំឯកទេស (SNF, Skilled Nursing Facility) ក្រុមអន្តរជំនាញអាចអនុម័តិការព្យាបាលសម្រាប់អ្នក ប្រសិនបើមិនមាននរណាម្នាក់ដែលមានសិទ្ធិស្របច្បាប់អាចសម្រេចចិត្តជំនួសអ្នកបានទេនោះ ។

## វិធីផ្សេងទៀតដើម្បីជួយអ្នកជាមួយនឹងទំនាក់ទំនងសង្គម/ផ្លូវភេទរបស់អ្នក ៖

សេវាកម្មនានាដែលមានសរសេរក្នុង IEP ឬ IPP របស់អ្នក អាចរួមបញ្ចូលនូវការជ្រោមជ្រែងនានា ដែលអាចជួយអ្នកអំពីទំនាក់ទំនងដូចជាការប្រឹក្សាយោបល់ សេវាកម្មការរស់នៅដោយឯករាជ្យ និងសេវាកម្មជ្រោមជ្រែងការរស់នៅ ។ អ្នកក៏អាចទទួលបានការអប់រំក្នុងវិស័យជំនាញសង្គម ការយល់ដឹងអំពីសុវត្ថិភាព និងរបៀបមានទំនាក់ទំនងល្អជាមួយនឹងអ្នកដទៃ ។ត្រង់នេះ អាចរួមបញ្ចូលនូវទំនាក់ទំនងជាមួយនឹងមិត្តប្រុស ឬមិត្តស្រី ។

## វិធីផ្សេងទៀតដើម្បីជួយអ្នកក្នុងការសម្រេចចិត្តលើការអប់រំ ៖

អ្នកអាចឲ្យអ្នកណាម្នាក់ដែលអ្នកជឿជាក់ធ្វើសេចក្តីសម្រេចចិត្តអំពីការអប់រំរបស់អ្នក ។ អ្នកអាចប្រគល់សិទ្ធិតាមច្បាប់ ឬសិទ្ធិក្នុងកិច្ចការសម្រេចចិត្តអំពីការអប់រំរបស់អ្នកឲ្យអ្នកដទៃ ។

**វិធីផ្សេងទៀតដើម្បីជួយអ្នកដាក់ពាក្យប្តឹងនៅតុលាការ ៖**

បើអ្នកចង់ដាក់ពាក្យប្តឹងនៅតុលាការ តុលាការអាចចាត់តាំងនរណាម្នាក់ឲ្យជួយអ្នកក្នុងការនិយាយជាមួយមេធាវីរបស់អ្នក និងការទំនាក់ទំនងជាមួយតុលាការ ។ បុគ្គលនេះត្រូវហៅថាអាណាព្យាបាលដែលបង្កើតឡើងដោយតុលាការ (Guardian ad Litem) ។ អាណាព្យាបាលដែលបង្កើតឡើងដោយតុលាការ នឹងដើរតួជារូបអ្នកនៅតុលាការ បើអ្នកមិនអាចទៅកាន់តុលាការ ឬមិនអាចយល់ភាសារបស់តុលាការបានទេនោះ ។

## 13. ចំពោះករណីផ្តល់អ្នកមើលការខុសត្រូវសម្រាប់ខ្ញុំ តើខ្ញុំត្រូវបង់ថ្លៃ និងការចំណាយតុលាការដែរឬទេ?

តុលាការនឹងកំណត់មើលថាតើអ្នកត្រូវបង់ថ្លៃដាក់ពាក្យប្តឹង ថ្លៃសេវាកម្មផ្លូវច្បាប់ និងថ្លៃចំណាយចំពោះតុលាការដែរឬទេ ។

## 14. តើអំណាចអ្វីដែលមិនមាននៅក្នុងការផ្តល់អ្នកមើលការខុសត្រូវដែលមានដែនកំណត់?

អ្នកមើលខុសត្រូវមិនអាច ៖
- គ្រប់គ្រងប្រាក់ពលកម្ម ឬប្រាក់ខែការងាររបស់អ្នកបានឡើយ
- ផ្តល់ការអនុម័តិចំពោះការព្យាបាលដែលមានគ្រោះថ្នាក់
- បង្ខំឲ្យមានការព្យាបាលដោយថ្នាំមកលើអ្នក
- ឲ្យអ្នកគ្រាវ ដើម្បីកុំឲ្យមានកូន
- ឲ្យអ្នកត្រូវតែទទួលការថែទាំពីមណ្ឌលណាមួយ
- យល់ព្រមឲ្យមានការព្យាបាលជម្ងឺវិកលចរិកដោយប្រើអគ្គិសនីឆក់ (ECT, electro-convulsive shock therapy)
- យល់ព្រមចំពោះការព្យាបាលចិត្តសាស្រ្ត
- មានអំណាចណាមួយផ្សេងទៀតដែលមិនបានបញ្ជាក់លាក់ពីតុលាការ ។

## 15. តើខ្ញុំមាននៅសល់សិទ្ធិអ្វីខ្លះចំពោះការមានមនុស្សមើលថែដែលមានដែនកំណត់?

អ្នកនៅមានសិទ្ធិដើម្បី ៖

- គ្រប់គ្រងប្រាក់ពលកម្ម ឬប្រាក់ខែរបស់អ្នក
- ធ្វើឬប្តូរបណ្តាំមរតកដើម្បីប្រាប់ថា តើនរណានឹងត្រូវទទួលបានរបស់របរផ្ទាល់ខ្លួនរបស់អ្នកពេលអ្នកស្លាប់
- រៀបការ ប្រសិនបើតុលាការមិនបានបញ្ជាក់ច្បាស់ថាខ្លួនដកសិទ្ធិនេះពីអ្នកទេនោះ
- ទទួលសំបុត្រផ្ទាល់ខ្លួន
- បោះឆ្នោត ប្រសិនបើតុលាការមិនបានបញ្ជាក់ច្បាស់ថាខ្លួនដកសិទ្ធិនេះពីអ្នកទេនោះ
- មានមេធាវីធ្វើជាអ្នកតំណាង
- ស្នើសុំអ្នកមើលការខុសត្រូវថ្មី
- ស្នើសុំឲ្យបញ្ចប់ភាពជាអ្នកមើលការខុសត្រូវ ។

## 16. តើខ្ញុំអាចធ្វើអ្វីបាន ប្រសិនបើខ្ញុំមិនយល់ស្របជាមួយអ្នកមើលការខុសត្រូវរបស់ខ្ញុំ ឬចង់បញ្ចប់ភាពជាអ្នកមើលការខុសត្រូវ?

- ហៅទូរស័ព្ទមកជួបមេធាវី អ្នកស៊ើបអង្កេតសុពលតុលាការ មជ្ឈមណ្ឌលប្រចាំតំបន់ កម្មវិធីថែទាំមនុស្សធំពេលថ្ងៃ បុគ្គលិកផ្នែកជ្រោមជ្រែង ឬអង្គការផ្នែកកិច្ចការនិយតកម្ម (OCRA, Organization Comprised of Regulatory Affairs) ។
- ស្នើសុំសវនាការតុលាការ ។
- ស្នើសុំមកកាន់អ្នកសម្របសម្រួលសេវាកម្មរបស់មជ្ឈមណ្ឌលប្រចាំតំបន់ (regional center service coordinator) ឲ្យមានការប្រជុំ IPP ។

## 17. តើភាពជាអ្នកមើលការខុសត្រូវដែលមានដែនកំណត់ត្រូវបញ្ចប់នៅពេលណា?

- នៅពេលដែលតុលាការប្រកាសបញ្ចប់ ។

- នៅពេលដែលអ្នកមើលការខុសត្រូវ ឬអ្នកដែលត្រូវគេមើលការខុសត្រូវស្លាប់ ។
- សេចក្តីបង្គាប់របស់តុលាការដែលនិយាយថា លែងត្រូវការឲ្យមានភាពជាអ្នកមើលការខុសត្រូវទៀតហើយ ។
- អ្នកមើលការខុសត្រូវដាក់ញត្តិទៅកាន់តុលាការស្នើសុំលាលែងពីភាពជាអ្នកមើលការខុសត្រូវ ។

## 18. តើក្រុមតស៊ូមតិដើម្បីសិទ្ធិអតិថិជន អាចជួយខ្ញុំបានដោយរបៀបណា (Clients' Rights Advocate)?

ក្រុមអ្នកតស៊ូមតិដើម្បីសិទ្ធិអតិថិជន អាចជួយអ្នកបានដោយការ ៖

- ប្រាប់អ្នកអំពីសិទ្ធិរបស់អ្នក
- ប្រាប់អ្នក ឬគ្រួសារអ្នកអំពីវិធីផ្សេងក្នុងការរកជំនួយក្រៅពីវិធីភាពជាអ្នកមើលការខុសត្រូវ
- និយាយជាមួយ ឬជួយអ្នកក្នុងការនិយាយជាមួយមេធាវី អ្នកស៊ើបអង្កេតសុពលតុលាការ និងអ្នកផ្សេងទៀតដែលអាចជួយអ្នកបាន ។

## 19. តើខ្ញុំអាចដឹងបានដោយរបៀបណាថា ភាពជាអ្នកមើលការខុសត្រូវមានដែនកំណត់ត្រូវបានបង្គាប់បញ្ជាដោយចៅក្រម?

- អ្នកនឹងទទួលបានសំណៅថតចម្លងសេចក្តីបង្គាប់របស់តុលាការ ។
- សេចក្តីបង្គាប់របស់តុលាការ នឹងប្រាប់អ្នកថាសិទ្ធិអ្វីខ្លះដែលត្រូវបានប្រគល់ទៅឲ្យអ្នកមើលការខុសត្រូវ ។

## 20. តើអ្នកដទៃអាចដឹងបានដោយរបៀបណាថាខ្ញុំមានអ្នកមើលការខុសត្រូវ?

អ្នកមើលខុសត្រូវ ត្រូវប្រគល់ឲ្យអ្នកដទៃនូវសំណៅថតចម្លងជាផ្លូវការនៃ**លិខិតបញ្ជាក់អំពីភាពជាអ្នកមើលការខុសត្រូវ (Letters of Conservatorship)**។សំណៅថតចម្លងនៃលិខិតនេះ ត្រូវរួមបញ្ចូលនូវ

វគ្គស្តីអំពីការបញ្ជាក់ពេញលេញនៃ **លិខិតភាពជាអ្នកមើលការខុសត្រូវ** នៅមុនពេលអ្នកនោះត្រូវបានគេចាត់ទុកថាជាអ្នកមើលការខុសត្រូវ ។

**ដើម្បីទទួលបានព័ត៌មានបន្ថែម សូមហៅទូរស័ព្ទមកកាន់**

**Disability Rights California**

**លេខហៅមិនបាច់អស់ប្រាក់ ៖ (800) 776-5746**

**ការិយាល័យតស៊ូមតិដើម្បីសិទ្ធិអតិថិជន**

**លេខហៅមិនបាច់អស់ប្រាក់ ៖ (800) 390-7032**

*អង្គការ Disability Rights California បានទទួលមូលនិធិពីប្រភពម្ចាស់ជំនួយផ្សេងៗ ។ ដើម្បីអានបញ្ជីទាំងស្រុងអំពីម្ចាស់ជំនួយ សូមទស្សនាគេហទំព័រ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html.